# បុរសក្នុងកំណាត់ហោតុ

និពន្ធដោយ យ៉ូជីណា ម៉ា
រចនាគ្របទំព័រដោយ EUGENEMA PIC.
ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង២ព្រឹក

«ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះការនិយមចូលចិត្ត អានអក្សរសាស្ត្រជាតិ ក៏ដូចជាស្នាដៃរបស់ខ្ញុំ។ សូមបញ្ជាក់ថា សាច់រឿង ឈ្មោះតួអង្គ ទីកន្លែង ពេលវេលា សុទ្ធតែជាការប្រឌិតពីអ្នកនិពន្ធ ទាំងអស់ ហើយដោយឡែក ការពិពណ៌នានេះទៀតសោត គឺជាការពិពណ៌នា ភាសាអារម្មណ៍របស់នារីភេទ ក្នុងសម័យខាងមុខ (មិនមែនសម័យនេះទេ) ដែលផ្ទុយស្រឡះ ពីអាកប្បកិរិយារបស់អ្នកនិពន្ធ។ អាស្រ័យហេតុនេះ ខ្ញុំបាទសូមមេត្តាអធ្យាស្រ័យទុកជាមុន កាលបើការពិពណ៌នានេះ ខុសពីអារម្មណ៍ពិតប្រាកដរបស់នារីភេទ។

សម្រាប់ការអាន សូមទស្សនិក មេត្តាអភ័យទោសទុកជាមុនផងដែរទៅចុះ ប្រសិនបើមានពាក្យពេចន៍ឆ្គាំឆ្គង ឬមិនសមរម្យ ឬមិនទាន់ដល់កម្រិត ដែលទស្សនិកជន បានស្រម៉ៃពីចំណងជើងរបស់អ្នកនិពន្ធ ដ្បិតដូចបានរៀបរាប់មកខាងលើផង ណាអ្នកនិពន្ធក៏ខានសរសេររឿងខ្លីមួយរយៈធំណាស់ហើយដែរ។ អាស្រ័យហេតុនេះ សូមមិត្តទស្សនិកជន និង អ្នកស្នេហាវិស័យអក្សរសាស្ត្រ ដ៏មានតម្លៃទាំងអស់ មេត្តាអធ្យាស្រ័យដល់អ្នកនិពន្ធ ជាមុនផងទៅចុះ។ ខ្ញុំបាទជាអ្នកនិពន្ធ នឹងចាំទទួលរាល់មតិរិះគន់ ក្នុងន័យស្ថាបនា ដ៏មានតម្លៃរបស់ទស្សនិកជនគ្រប់ពេលវេលាជានិច្ច។ សូមអរគុណ!! »

ពីខ្ញុំ យ៉ូជីណា!

យូរឆ្នាំហើយ ដែលខ្ញុំខានបើកកំណត់ហេតុរបស់ខ្ញុំ។ យូរឆ្នាំហើយ ពេលវេលា ដែលធ្លាប់ស្រស់ស្អាតប៉ុន្មាន ក៏ត្រូវធូលី និងសម្បុកពីងពាង ប្រជែងគ្នាហ៊ុមព័ទ្ធ ប្រឡាក់ពេញទាំងគម្រប់សៀវភៅរបស់ខ្ញុំ។ ខ្ញុំបានរលាស់សៀវភៅឡើង បណ្ដាលឲ្យធូលីហុយត្រលោម ពេញទាំងបន្ទប់ដាក់សៀវភៅរបស់ខ្ញុំ។ នៅទំព័រទី១ក្នុងសៀវភៅរបស់ខ្ញុំ បានសរសេរឡើងថា «សៀវភៅកំណត់ហេតុប្រចាំថ្ងៃ ឆ្នាំ២០១០»។

*ភ្នំពេញ ចូលឆ្នាំខ្មែរ ឆ្នាំ២០១០,*

ថ្ងៃនេះ ជាពិធីបុណ្យដ៏ធំមួយរបស់ខ្មែរយើង ប៉ុន្តែសម្រាប់ខ្ញុំ គឺជាថ្ងៃដែលធុញទ្រាន់ទៅវិញ ព្រោះខ្ញុំជាអ្នកភ្នំពេញ ដែលមានលោកប៉ាមមាញឹកនៅជាមួយនឹងខែត្រហេតុ!!!

ថ្ងៃឈប់សម្រាកដ៏ធុញទ្រាន់របស់ខ្ញុំ បានចូលមកដល់ទៀតហើយ។ ☹ ដូចរាល់ឆ្នាំអ៊ីចឹង ទិដ្ឋភាពនានា តាមដងវិថី ក្នុងអំឡុងពេលល្ងាច នៃថ្ងៃមួយនេះ មានសភាពស្ងាត់ស្ងៀមណាស់។ ម្ដងម្កាល ខ្ញុំសង្កេតឃើញមានរថយន្តមួយៗប៉ុណ្ណោះ បរចុះបរឡើង។

ខ្ញុំកំពុងឈរមើលដងផ្លូវពីបង្កាន់ដៃផ្ទះរបស់ខ្ញុំ ជាមួយនឹងពន្លឺភ្លើងពណ៌ក្រហម ដែលផ្ដល់ពីដងវិថី នៅខាងមុខរានហាលផ្ទះរបស់ខ្ញុំ។ ខាងក្រោយខ្ញុំ មានដង្វាយរៀបចំទទួលទេព្ដាឆ្នាំថ្មី។

ខណៈនេះ ខ្ញុំអង្គុយលើគ្រែ។ ខ្ញុំបើកទូរទស្សន៍។ ដូរគ្រប់ប៉ុស្តិ៍ហើយ ឃើញតែគេនិយាយពី ព្រឹត្តិការណ៍ចូលឆ្នាំ។ ខ្ញុំបិទទូរទស្សន៍ ខ្ញុំគេងមើលសៀវភៅ។ នៅក្នុងបន្ទប់មានតែខ្ញុំ តែម្នាក់ប៉ុណ្ណោះ។

តុកៗ! សំឡេងគោះទ្វាបានបន្លឺឡើង។ ខ្ញុំដើរទៅមើលទាំងប្រុងប្រយ័ត្ន។ ខ្ញុំទាញត្បាល់បុកមួយនៅដៃ រួចជាស្រេច។

- អ្នកណាណឹង?
- សូមទោស ខ្ញុំសូមសួរមួយបានទេ។

សំឡេងមនុស្សប្រុសម្នាក់ ដែលមានសម្ដីទន់ភ្លន់ ដូចតួនៅក្នុងរឿងកុន ដែលខ្ញុំមើលរាល់យប់ម្នាក់ បានបន្លឺឡើង។

- លោកមានការអីណឹង?

ខ្ញុំលួចអើតមើល តាមរន្ធកែវតូចមួយដែលដាក់ នៅជាប់នឹងទ្វារ។ បុរសម្នាក់ មានសំលៀកបំពាក់ អាវធំ ជាមួយនឹងអាវយឺតសខាងក្នុង នៅលើមុខរបស់គេ ដៃរបស់គេ ទាញវ៉ែនតា តម្រង់ចុះ តម្រង់ឡើងរហូត។ បើតាមខ្ញុំស្មានមើលទៅ គេទំនង ជាអ្នកដំណើរមកពីឆ្ងាយហើយ ព្រោះក្នុងដៃរបស់គេ មានកាន់វ៉ាលីអូសមួយទៀត។

- អត់ទោស តើនៅទីនេះមានឈ្មោះ កញ្ញា នីដា ទេ?
- លោករកនាងម្នាក់នោះធ្វើអីទៅ?
- ខ្ញុំឈ្មោះ ទេព សាយុទ្ធ មកពីប្រទេសកាណាដា។ ខ្ញុំមកទីនេះ ដើម្បីរកនាង និយាយគ្នាពីរឿងមួយ។
- រឿងអីទៅ?
- សូមទោសផង ខ្ញុំមិនអាចប្រាប់បានទេ! នេះជារឿងសម្ងាត់របស់នាងនិងខ្ញុំ។
- រឿងសម្ងាត់? អូហ៍! អ៊ីចឹង ខ្ញុំមិនស្គាល់នាងនោះទេ។

ខ្ញុំសង្កេតឃើញលោកម្នាក់នោះ ព្យាយាមពិនិត្យមើលក្រដាស់ម្តងហើយម្តងទៀត រួចព្យាយាមមើលទៅស្លាកអាសយដ្ឋានបន្ទប់ជួលខ្ញុំ។ ទោះបីជាមែនក៏ដោយ ក៏ខ្ញុំមិនស្គាល់លោកម្នាក់នោះដែរ។ ខ្ញុំក៏ប្រញាប់ទូរស័ព្ទទៅលោកប៉ាភ្លាមៗ!

- អាឡូ! ប៉ា!
- នេះ តើឯងមានឃើញ លោកយុទ្ធ គេទៅដល់ផ្ទះឯងហើយឬនៅ? ប៉ាទៅដល់ផ្ទះតឡូវហើយ។
- ឃើញហើយ គេនោះជាអ្នកណា?
- ឆាប់ទៅតាមគេភ្លាមទៅ ប៉ាមកដល់តឡូវហើយ។ គេនោះជាបងប្អូនជីដូនមួយសាច់ឆ្ងាយរបស់ឯងណា!
- បងប្អូនជីដូនមួយម៉េចក៏ខ្ញុំមិនដឹង!

មកពីខ្ញុំសង្ស័យពេកហើយ បានជាបែបនេះ។ ប៉ុន្តែ ខ្ញុំជាមនុស្សស្រី គេជាមនុស្សប្រុស ហើយយើងមិនដែលស្គាល់គ្នាទៀត រឿងអីខ្ញុំខុស មែនទេ?

- អេ! អេ! ឈប់សិនលោក។ -_-`

គាត់ចុះជិតដល់ក្រោមហើយ។ ខ្ញុំខំស្រែកហៅគាត់ រហូតដល់របូតជើងជាន់ខុសកាំជណ្តើរបណ្តាលឲ្យដួល។ គេឃើញខ្ញុំបែបនេះ គេក៏រត់មកយ៉ាងលឿន រួចលើកខ្ញុំ តែខ្ញុំព្យាយាមទាញដៃគេចេញ។

ខ្ញុំអង្គុយលើសាឡុង។

- ថ្នាំរឺត នៅកន្លែងនោះ… អូយ! ☹
- បាទ! ចាំម៉ាភ្លែត ខ្ញុំកំពុងតែរកហើយ។

គេហាក់ដូចជាយកចិត្តទុកដាក់ខ្ញុំណាស់ ទោះជាយើងទើបតែស្គាល់គ្នាក៏ដោយ។

គេរកយ៉ាងប្រញ៉ាប់ប្រញ៉ាល់។

- យ៉ាងម៉េចហើយ?
- បានហើយៗ ខ្ញុំរឺតខ្លួនឯងបានហើយ។ :P

គេស្ដាប់បង្គាប់គ្រាន់បើ គ្រាន់តែខ្ញុំនិយាយបានប៉ុណ្ណោះ គេក៏ហុចថ្នាំរឹតឲ្យខ្ញុំ។ ខ្ញុំក៏ទទួលពីគេ ចំណែកគេ គេក៏ឃិតទៅម្ខាង ហើយតម្រង់ វ៉ែនតាទៀតហើយ។ :P

- សូមទោសផង ដែលខ្ញុំមិនបានគួរសមដាក់លោក។
- បាទ! មិនអីទេ។ ^_^´

គេញញឹមដាក់ខ្ញុំបណ្ដើរ គេអោនមុខចុះបណ្ដើរ។ គេសុភាពគ្រាន់បើ។ គេអង្គុយស្ងៀមធ្មឹង។ មួយសន្ទុះក្រោយមក សំឡេងគោះទ្វារក៏បន្លឺឡើង ជាថ្មី។

- នីដា! បើកទ្វារឲ្យប៉ា។
- ចាំ! ប៉ា! ចាំម៉ាភ្លែតសិន!

ខ្ញុំប្រឹងងើប តែជើងរបស់ខ្ញុំ មិនព្រមងើបតាមសោះ វាហាក់ធ្វើមុខក្រញ៉ូវដាក់ខ្ញុំអ៊ីចឹង។ ខ្ញុំងើបបិះដួល បើកុំតែលោកម្នាក់នោះ ចាប់ដៃទាន់ កុំអីខ្ញុំដួលទីណាត់ទីណែងហើយ។ គេទៅបើកទ្វារជំនួសខ្ញុំ។

- មិនចេះប្រយ័ត្នប្រយែងសោះកូននេះ។

ប៉ាស៊ីឲ្យខ្ញុំបណ្ដើរដៃគាត់ប្រឹងរឹតជើងឲ្យខ្ញុំបណ្ដើរ។ ខ្ញុំមិនហ៊ានតមាត់អ្វីនោះទេ ខ្លាចខ្មាស់បុរសម្នាក់នោះ។ នេះជាលើកទីមួយហើយដែលបន្ទប់ជួលរបស់ខ្ញុំ មានមនុស្សប្រុសក្រៅពីប៉ា អង្គុយក្នុង។

- សូមទោសផងណា យុទ្ធ! គេតែងតែអ៊ីចឹង។ និយាយអ៊ីចឹង! ម៉ាក់ប៉ាយុទ្ធសុខសប្បាយទេ?
- បាទ! មិនអីទេលោកពូ! ពួកគាត់សុខសប្បាយតើ! ចុះខាងលោកពូវិញ?
- អូហ៍! ដូចក្មួយបានដឹងហើយ ពូសុខជាធម្មតាទេ តែពូរវល់ណាស់មួយរយៈនេះ រកពេលតែមកលេងកូនក៏មិនបានផង។ នេះចូលឆ្នាំថ្មីផង!
- អូ! នីដា ជាកូនរបស់លោកពូ?

យី! គេនិយាយដូចភ្ញាក់ផ្អើលណាស់ មុខខ្ញុំដូចប៉ាខ្ញុំប៉ុណ្ណឹងហើយ នៅតែមើលមិនដឹងទៀត។ :P

- ហាហ! ហាហ! គេជាកូនពូ! នែក! នីដា! យុទ្ធជាបងជីដូនមួយរបស់ឯង។ យុទ្ធ គេជានីដាដែលឯងឃើញតាំងពីតូចនោះអី!

ប៉ាមើលមុខខ្ញុំ រួចដៃរបស់គាត់លើកជើងរបស់ខ្ញុំដាក់នៅលើដីវិញតាមសម្រួល។

- បាទ! លោកពូ! សួស្ដីនីដា!

គេចាំខ្ញុំ ម៉េចក៏ខ្ញុំមិនចាំគេអ៊ីចឹង។ ខ្ញុំព្យាយាមរកនឹកគេម្ដងហើយ ម្ដងទៀត តែរកនឹកមិនឃើញសោះ។ ខ្ញុំមិនតបជាមួយគេទេ គ្រាន់តែញញឹមបន្ដិច ហើយបែរមុខចេញវិញ។ ពេលនោះ ប៉ាក៏មានប្រសាសន៍កាត់៖

- អូ! នែក! នីដា! យប់នេះ ប៉ានិងយុទ្ធ សូមគេងនៅផ្ទះកូនមួយយប់ហើយណា! មើល៍! នែក! កូនប្រហែលជាមិនប្រកាន់លោកប៉ានោះទេ មែនទេ?

ប៉ាមានប្រសាសន៍មកកាន់ខ្ញុំ ទាំងមើលមុខខ្ញុំចំៗតែម្តង។ ខ្ញុំឱនមុខចុះបន្តិច។

- ចាំបាច់សូមអីប៉ា ដូចតែផ្ទះប៉ាទៅហើយ តែលោក...
- យុទ្ធអេ្ហ! មិនអីទេ គេគេងជាមួយប៉ាបានហើយ!
- អូហ៍! មិនអីទេលោកពូ ខ្ញុំអាចគេងលើសាឡុងនេះបានហើយ។ លោកពូអាចចូលសម្រាន្តនៅខាងក្នុងចុះ។
- មិនកើតទេ! យុទ្ធជាភ្ញៀវ ពូណា!
- មិនអីទេ! ខ្ញុំខ្លាចចិត្តលោកពូណាស់។ បើលោកពូ នៅតែឲ្យខ្ញុំចូលទៅក្នុងទៀត ខ្ញុំនឹងរៀបចំឥវ៉ាន់ទៅគេងសណ្ឋាគារវិញហើយ។
- នែក...

ប៉ាទាស់យោបល់! មើលទៅគេ ដូចជាមធ្យ័តណាស់! គេត្រូវគេងខាងក្រៅ មែនហើយ។ ខ្ញុំមើលមុខប៉ា ប៉ាមើលមុខខ្ញុំ។ រាត្រីចូលមកដល់ គេគេងក្នុងមុង។ ខ្ញុំគេងក្នុងបន្ទប់ ចំណែកលោកប៉ា គាត់សម្រាន្តហើយ គ្រាន់តែលាគ្នាភ្លាម។

យប់នេះ ខ្ញុំដូចជារសាប់រសល់យ៉ាងម៉េចមិនដឹងនោះទេ ម៉ោងជិត១២ហើយ។ ខ្ញុំគេងមើលប្រលោមលោកដូចយប់រាល់ដងអ៊ីចឹង តែមើលជិតអស់មួយក្បាលទៅហើយ នៅតែគេងមិនលក់សោះ។ យប់នេះ ខ្ញុំមើលតពីសាច់រឿងភាគមុន ដល់ត្រង់បុរសម្នាក់ បានមកជួលបន្ទប់ជិតនារីម្នាក់។ ហើយបុរសម្នាក់នោះ តែងកំណាព្យជូនសង្សារ ដែលព្រាត់ពីគ្នាយូរមកហើយ។ និយាយទៅ ខ្ញុំចូលចិត្តប្រលោមលោក និងកំណាព្យណាស់។ ពិសេសចូលចិត្ត ការពិពណ៌នារបស់ អ្នកនិពន្ធ នូ ហាច ជាងគេ។ ខ្ញុំហាក់ដូចជាស្រឡាញ់តួ ទាយាវុធ ណាស់។ ខ្ញុំតែងគេងស្រម៉ៃរាល់យប់ថា ថ្ងៃណាអាចជួបបុរស ដែលចេះយល់ចិត្ត និងពូកែតែងកំណាព្យបែបរូបគេនោះ។ ☺

- ភាសារាត្រីស្ដីបំភ្លើស យប់ស្ងាត់មេឃរើសពណ៌ងងឹត ដួងចន្ទ្រយប់នេះដូចដួងចិត្ត ស្រពោនក្រៀមស្វិតឥតពន្លឺ...

សំឡេងកំណាព្យល្វើយៗ មិនដឹងមកពីណា។ ខ្ញុំក៏ចាប់ញីត្រចៀករបស់ខ្ញុំ ក្រែងជាការសុបិន។ ខ្ញុំនៅតែឮសំនៀងអ្នកសូត្រកំណាព្យនេះរហូត ល្ហិកណា ពេលដែលទ្វាររបស់ខ្ញុំ បានរបើកឡើងតិចៗ ក្នុងស្បៃរាត្រី។

- ពីតូចពេញវ័យក្ដីស្រម៉ៃ នឹកពៅរាល់ថ្ងៃឥតមានលួស ធ្លាប់សើចសប្បាយធ្លាប់រួមរស់ បែកគ្នាក៏ព្រោះត្រូវចេញឆ្ងាយ...

កំណាព្យក៏ដាច់ត្រឹមណេះ អ្នកសូត្រក៏ស្ងាត់។ ស្រមោលបុរសម្នាក់ ឈរក្បែរបង្កាន់ដៃ ងាកក្រោយបន្តិច ហើយក៏ឈរញាំតែ តែម្នាក់ឯង។ ជើងខ្ញុំលោតតិចៗ! លាន់សូរ ក្អុក!

- ជើងនីជាយ៉ាងម៉េចហើយ?
- អូហ៍! លោកមិនទាន់គេងទេឬ?

ខ្ញុំសួរដំណាលគ្នាជាមួយគេ។ ខ្ញុំឈរម្ខាង គេឈរម្ខាង។ យើងផ្អាកចម្លើយទាំងអស់គ្នា ខ្ញុំមើលលើតាមគេទៅលើ។

- មានអីនៅលើនោះ បានជាមើលអត់ឈប់អ៊ីចឹង?
- មុននេះ មានទេពច្យុត មួយកំពុងតែចុះមក ខ្ញុំកំពុងតែចាំមើល ក្រែងលោមានមួយទៀត។
- ទេពច្យុត? ពិតជាមានទេពច្យុត មែនហ្ហ?
- បាទ!

លោកនេះ ឆ្លើយមួយម៉ាត់ៗប៉ុណ្ណោះ។ ពាក្យដែលខ្ញុំឮច្រើនជាងគេ គឺ បាទ បាទ! ធុញណាស់! តែក៏ពិរោះដែរ។ រាត្រីយប់ស្ងាត់ណាស់ហើយ លើមេឃស្រឡះល្អណាស់ គឺស្រឡះល្អមនឹងអាច មើលឃើញផ្កាយក្នុងក្រឡពេជ្រ នៃភពងងឹត ដ៏ធំល្វឹងល្វើយ។

- ទេពច្យុត ណឹងម៉េចទៅ? ខ្ញុំធ្លាប់តែឮក្នុងប្រលោមលោក។ ខ្ញុំសួរគេបញ្ជាក់។ គេមើលមុខខ្ញុំ ហើយសើចបន្តិច។
- វាមានកន្ទុយវែង ខុសពីផ្កាយដទៃ។ មនុស្សម្នា មិនងាយឃើញវាដោយងាយនោះទេ។ មានជំនឿមួយ គេនិយាយថា កាលណា ទេពច្យុត បង្ហាញខ្លួន នឹងមាន អ្នកមានបុណ្យចាប់កំណើតលើ ភពផែនដីយើងនេះ។
- គ្រាន់តែប៉ុណ្ណឹង តើទៅចាំមើលវាធ្វើអី នាំតែធុញទ្រាន់នោះទេ!
- មកពីមានជំនឿនោះហើយ ទើបបានជា នៅពេលដែលគេឃើញ គេតែងតែបន់ស្រន់ ព្រោះមិនងាយឃើញបែបនេះ ទើបការបន់ស្រន់សក្តិសិទ្ធិ។
- អូហ៍! ... អ្ហឺ! ចុះលោកមុននេះ មានបន់ស្រន់ដែរ ហ៎?

គេសើចបន្តិច រួចមើលទៅដងផ្លូវដ៏សែនស្ងាត់ ក្នុងពិធីបុណ្យចូលឆ្នាំនៅភ្នំពេញយើង។ ខ្ញុំប្រហែលជាសួរគេច្រើនពេកហើយ។ អ៊ីចឹង ក៏មានអារម្មណ៍ថា អៀនគេណាស់។ ខ្ញុំអេសក្បាលតិចៗ ហើយប្រឹងមើលទៅលើ។ នេះប្រហែលជានិស្ស័យហើយ ខ្ញុំគ្រាន់តែក្រឡេកលេង ឡើងទៅមើលផ្ទៃមេឃដ៏ធំល្វឹងល្វើយ ស្រាប់តែឃើញ ទេពច្យុតមួយ ស្រយ៉ុតខ្លួនចុះមក។ ខ្ញុំក៏ចាប់គេសគេ ដោយមិនដឹងខ្លួនសោះ។

- ឆាប់បន់ស្រន់ទៅនីជា! មានសំណាងល្អណាស់!

ខ្ញុំលើកដៃប្រណម្យបន់ស្រន់ ឲ្យជួបបុរសម្នាក់ក្នុងសុបិន ហើយនិងជួបគេជារៀងរហូត ទោះជាយ៉ាងណាក៏ដោយ។ ខ្ញុំបើកភ្នែកវិញ គេក៏ចូលគេងបាត់ទៅហើយ។ បុរសម្នាក់នេះ ស្ងប់ស្ងៀមណាស់ គេដូចជាអំពិលអំពេកអ៊ីចឹង។

«បុរសអំពិលអំពេក» នេះជាឈ្មោះចំណងជើងក្នុងសន្លឹកមួយដ៏ចាស់ នៃសៀវភៅកំណត់ហេតុរបស់ខ្ញុំ។ ថ្ងៃនោះហើយ ជាថ្ងៃដែលខ្ញុំជួបគេដំបូង ហើយក៏ប្រហែលជាយប់ចុងក្រោយដែរ ដែលខ្ញុំជួបគេ។ ខ្ញុំបើកសៀវភៅទៅទំព័រមួយទៀត។ សន្លឹកផ្កាឈូករ័ត្នក្រៀមមួយ នៅតែបិតបេរ។ ទោះជាវាក្រៀមស្រពោនក៏ដោយ ហើយទងរបស់វាបានបាត់អស់ក៏ដោយ តែវានៅតែបិតបេរ ដូចជាចិត្តនារីម្នាក់ ដែលកប់រឿងមួយទុកក្នុងចិត្តរហូត មកអ៊ីចឹង។

- ប៉ា! កូនធ្វើម្ហូបរួចរាល់ហើយ។ ប៉ា! ក្រោកឡើង! ពិសាបាយ!
- អឺ! ចាំម៉ាភ្លែត ! ប៉ាងូតទឹកតិចសិន!

ខ្ញុំគោះទ្វារបន្ទប់ប៉ា ហើយព្យាយាមក្រឡេកមើល កន្លែងគេងរបស់លោកទេព សាយ៉ុត នោះដែរ តែឃើញតែ សៀវភៅមួយក្បាលប៉ុណ្ណោះដាក់ចោលនៅទីនោះ។ សាឡុង និងទីកន្លែង រៀបរយគ្រាន់បើ។ គេស្ងប់ស្ងាត់ណាស់ តែគេមានចំណុចមិនល្អមួយ គឺចូលបន្ទប់ទឹកយូរ។ >_<

ខ្ញុំដើរទៅផ្ទះបាយ ខាងក្រោយ ដោយងាកក្រោយបណ្ដើរ ដើរទៅមុខបណ្ដើរ លែងអី! ស្រាប់តែបុកលោកទេពសាយុទ្ធ ដោយមិនដឹងខ្លួន។ ខ្ញុំក៏ដួលនៅលើដី តែក៏ត្រូវលោកម្នាក់នោះចាប់ដៃជាប់ទៀតហើយ។ ខ្ញុំព្យាយាមដកដៃចេញភ្លាម។

- អីយូយ! ~_~´
- នីដា! យ៉ាងម៉េចហើយ?
- អត់អី… អត់អីទេ…? លែងដៃខ្ញុំ! មិនអីទេ! អូយ!……
- មិន… មិនអីទេ ចាំខ្ញុំនាំនីដា ទៅកាន់កៅអីសិនណា!

ដៃរបស់គេត្រជាក់ណាស់ គេចាប់គួយដៃរបស់ខ្ញុំតិចៗ ហើយទាញកៅអីឲ្យអង្គុយ។

- សូមទោសផង!
- បាទ! មិនអីទេ! នីដាយ៉ាងម៉េចហើយ?
- ចំា! មិនអីទេ! អរគុណ! អរគុណហើយ…
- នីដា ចូលចិត្តផ្កា អីដែរ?

- ផ្កា?

ខ្ញុំភ្ញាក់ព្រើត ពេលដែលគេសួរសំណួរមួយនេះ! គេប្រហែលជាមើលឃើញ ថូផ្កា ដែលមានតែទឹក នៅលើតុបាយ របស់ខ្ញុំនោះហើយ។

- បាទ! ផ្កា! ព្រោះខ្ញុំឃើញ ថូផ្ការបស់អ្នកនាងរាងធំខុសពី ទម្រង់ផ្កាដទៃ។
- ហិហិហិហ! មិនលាក់បាំងទេ ខ្ញុំចូលចិត្តផ្កាឈូករ័ត្នណាស់។ ^_^´

យើងញ៉ាំអាហារជុំគ្នា។ ថ្ងៃនេះជាថ្ងៃទីមួយហើយ ដែលមានបុរសទី២ក្រៅពីលោកប៉ា មកញ៉ាំអាហារពេលព្រឹកក្នុងផ្ទះខ្ញុំ។ អារម្មណ៍ខ្ញុំ ហាក់ដូចជាមិនជាប់ពីខ្លួនយ៉ាងម៉េចទេ។ ហ្អើយ! ខ្មាស់គេណាស់ កំពុងរកមើលគេហើយ បែរជាទៅប៉ះគេទៅវិញ។

- ព្រឹកនេះ ខ្ញុំនឹងជូនយុទ្ធទៅសៀមរាប ហើយ ខ្ញុំនឹងជូនលោក ជិះយន្តហោះ ត្រឡប់មកភ្នំពេញវិញ រួចខ្ញុំនឹងជូនយុទ្ធឡើងយន្តហោះ នៅថ្ងៃទី៣ណា។

លោកប៉ាចាប់មានប្រសាសន៍ឡើង។

- ថ្ងៃខានស្អែកនេះ...ហ៎ ប៉ា?

មិនដឹងជាអារម្មណ៍ទៅណានោះទេ ខ្ញុំស្រាប់តែឆ្លេយមាត់ ឧទានសំណួរនេះឡើង។ គេទាំងអស់គ្នា មើលមុខខ្ញុំគ្រប់គ្នា។

- អ្ហឺ...! ខ្ញុំចង់សួរថា ថ្ងៃខានស្អែកនេះ យុទ្ធទៅវិញហើយ មែនទេ? ^_^´ ហិហិហ!

ម្នាក់ៗ ស្ញៀមបន្តិច ហើយយុទ្ធក៏ដាច់ចិត្តនិយាយមុន។

- អូហ៍! មែនហើយ ខ្ញុំត្រូវត្រឡប់ទៅវិញ ថ្ងៃខានស្អែកនេះមែន ព្រោះនេះ ប្រហែលជាដំណើរ លើកទី១របស់ខ្ញុំហើយ ហើយក៏ប្រហែលជាលើកចុងក្រោយរបស់ខ្ញុំដែរ...

«ហើយក៏ប្រហែលជាលើកចុងក្រោយរបស់ខ្ញុំដែរ...» ពាក្យនេះ តែងតែទន្ទេញជាប់ចិត្តខ្ញុំជានិច្ច។ ខ្ញុំចាក់សោរផ្ទះរួច។ ខ្ញុំក៏ចុះទៅក្រោម។ រួចបើកឡានជូន ប៉ាទៅយក ឡាននៅឃ្លាំងឡាន ក្បែរផ្ទះជួលរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាប្លែកណាស់ តែក៏ប្រឹងបំភ្លេចចោល។

- នីដា! នីដា! ហួសផ្លូវហើយ...

សំឡេងប៉ារបស់ខ្ញុំបន្លឺឡើង! ម្តងទៀតហើយ ខ្ញុំត្រូវខ្មាស់គេជាថ្មី។ ខ្ញុំមកដល់កន្លែងដាក់ឡានប៉ាហើយ។ គេជិតទៅឆ្ងាយខ្ញុំហើយ... ហេតុអីក៏ខ្ញុំ ហាក់ដូចជាស្គាល់គ្នាជាមួយគេយូរមកម្ល៉េះហើយ។ ខ្ញុំទទួលអារម្មណ៍ថា ខ្ញុំហាក់ដូចជាធ្លាប់ជួបគេ និងជិតស្និទ្ធិនឹងគេយូរណាស់មកហើយ។

- សុខសប្បាយណាលោកប៉ា!

កញ្ចក់ប៉ារបស់ខ្ញុំ ក៏បង្ហូតឡើង គាត់ញញឹមហើយលើកដៃគ្រវីបន្តិច ជាសញ្ញាថា គាត់ត្រូវចេញទៅហើយ។

«ថ្ងៃដែលមិនអាចវិលវិញ» នេះជាចំណងជើងថ្ងៃទី២ក្នុងទិវាចូលឆ្នាំ ក្នុងថ្ងៃនោះ។ ខ្ញុំរៀបសន្លឹកផ្កាឈូករ័ត្នក្រៀម ឲ្យស្អាតជាថ្មី រួចបន្តបើកសៀវភៅទៅទំព័របន្ទាប់។ តែមិនទាន់បានបើកផង ជើងរបស់ខ្ញុំ ក៏ជាន់សៀវភៅមួយទៀត។ ខ្ញុំរើសវាឡើង ហើយប្រឹងក្រលាស់ដី និងសំណាញ់ពីងពាងជាថ្មី។

ខ្ញុំមកដល់ផ្ទះវិញហើយ។ ថ្ងៃនេះ ផ្ទះខ្ញុំស្ងប់ស្ងាត់ទៀតហើយ។ ដូចជាសុបិនមួយគ្រាអ៊ីចឹង។ ខ្ញុំជួបមនុស្សម្នាក់ ចំពេលដែលមិនត្រូវជួបគ្នា។ មុនចេញទៅ គេចាំបាច់ប្រាប់ថា គេទៅប្រហែលជាមិនត្រឡប់វិញដែរឬ? គេនេះ ប្រហែលជាចង់ធ្វើឲ្យខ្ញុំទន់ចិត្តអាណិតគេហើយ។ អេ! នេះផ្កាឈូករ័ត្នរបស់អ្នកណា? ព្រឹកមិញ ខ្ញុំដូចជាមិនបានទៅផ្សារនោះទេ។ ហេតុអីក៏......?

ពេលនោះ សម្ដីមនុស្សម្នាក់ក៏និមិត្តខ្ញុំចិត្តខ្ញុំឡើងជាថ្មី។ វាមានសំនៀងផ្អែមពិរោះ ដូចធ្លាប់ឮ នោះគឺ «នីដា ចូលចិត្តផ្កា អីដែរ?» សំនៀងនេះហើយ ដែលខ្ញុំនឹកឃើញ។ នេះប្រហែលជាផ្កាឈូករត្ន័របស់លោកយុទ្ធអីនោះហើយ។

ខ្ញុំដើរបណ្ដើរកាន់ផ្កាបណ្ដើរ ហើយក៏គិតបណ្ដើរដែរ។ ខ្ញុំអង្គុយចុះនៅលើសាឡុង ក៏ស្រាប់តែគិនសៀវភៅមួយក្បាល។ សៀវភៅនោះ គឺសៀវភៅរបស់លោកយុទ្ធនោះទៀតហើយ។ លោកនោះមានបំណងអ្វីអ៊ីចេះ?

ខ្ញុំបើកមើលសៀវភៅ ឃើញគេសរសេរថា «សៀវភៅកំណត់ហេតុ»។ ពេលនោះ ខ្ញុំក៏រួសរាន់ទូរស័ព្ទទៅលោកប៉ាភ្លាមឲ្យមកយកវិញ ប៉ុន្តែលោកប៉ាបានមានប្រសាសន៍ថា ទុកនៅទីនោះសិនហើយ ព្រោះយុទ្ធ ប្រញ៉ាប់ ហើយចាំពេលដែលមកភ្នំពេញវិញ ចាំយកត្រឡប់ទៅវិញ។ ខ្ញុំក៏ត្រូវរក្សាទុកសៀវភៅសម្ងាត់របស់គេ ដោយមិនហ៊ានបើកមើលនោះទេ ព្រោះក្រែងថាយើងចេះលួចមើលរឿងរបស់គេ។

ស្អែកឡើងចូលមកដល់ ខ្ញុំរៀបចំផ្ទះ។ ខ្ញុំដូរទឹកដាក់ឲ្យផ្កាឈូករ័ត្ន។ ផ្កាឈូករ័ត្នមានឈ្មោះជាភាសាអង់គ្លេសថា «Sun flower» ឬ ផ្កាព្រះអាទិត្យ។ ខ្ញុំដាក់ឈូករ័ត្នឲ្យត្រូវថ្ងៃ។ ខ្ញុំរៀបចំសៀវភៅ។ ដោយមិនបានប្រយ័ត្ន ខ្ញុំក៏ប៉ះសៀវភៅលោកយុទ្ធ បណ្ដាលឲ្យធ្លាក់ ស្រាប់តែក៏ប្រទះឃើញ ចំណងជើងរឿងមួយសរសេរថា «នារីក្នុងកំណត់ហេតុរបស់ខ្ញុំ»។

ចំណាងជើងនេះប្លែកណាស់។ ដឹងស្រាប់ហើយ ខ្ញុំជាអ្នកប្រលោមលោកនិយម។ សេចក្ដីជឿងឆ្ងល់របស់ខ្ញុំ ក៏បណ្ដាលឲ្យចិត្តខ្ញុំ ធ្វើខុសពីសច្ចៈធម៌នៃចិត្ត។

«នារីក្នុងកំណត់ហេតុរបស់ខ្ញុំ»
ភាសារាត្រីស្ដីបំភ្លើស
យប់ស្ងាត់មេឃរើសពណ៌ងងឹត
ដួងចន្ទ្រយប់នេះដូចដួងចិត្ត
ស្រពោនក្រៀមស្វិតចិត្តរងារ។
យើងជួបគ្នាហើយតែមិនចាំ
ភ្លេចអស់ទីឆ្នាំធ្លាប់ជួបគ្នា
ឥឡូវបានជួបជួបមួយគ្រា
ថ្ងៃស្អែកត្រូវលាទាំងមិនមាត់។
ថាគេនៅចាំថាគេភ្លេច
តែធ្វើដូចម្ដេចជួបហើយព្រាត់
ជារឿងមនុស្សលោកកត់ប្រវត្តិ
ចងចាំរឿងព្រាត់ជួបតែគ្រោះ។
ពីតូចពេញវ័យក្ដីស្រម៉ៃ
នឹកពៅរាល់ថ្ងៃឥតមានល្ហួស
ធ្លាប់សើចសប្បាយធ្លាប់រួមរស់
បែកគ្នាក៏ព្រោះត្រូវរស់ឆ្ងាយ។
ឥឡូវស្ងួនធំម៉ុមនួននាង
ពេញរូបពេញរាងប្លែកទាំងកាយ
ពៅល្អទាំងព្រមគន់មិនណាយ
តែកម្មនាំឆ្ងាយឆ្ងាយម្ដងទៀត។
ឆ្នាយនេះមិនដឹងថ្ងៃត្រឡប់
អស់ពេលបញ្ចប់ចិត្តឃ្លៀងឃ្លាត
ឃ្លាតទាំងវាចាចារនាថ
ជាប់ទ្រូងចង្អៀតស្ដីមិនចេញ។

កំណត់ហេតុដួងចិត្តខ្ញុំអើយ
យើងព្រាត់គ្នាហើយ ខ្ញុំទម្ងេញ
ម្ដេចចារឲ្យជួបចារឲ្យចេញ
មនុស្សខ្ញុំស្រឡាញ់លាក់ក្នុងចិត្ត

គេតែងមិនទាន់ពេញចិត្តខ្ញុំនៅឡើយទេ...... តែកំណាព្យគេបានធ្វើឲ្យទឹកភ្នែកដែលហាក់ដូចជាត្រាំទុកក្នុងល្អាងទុក្ខសោកមកជាយូរ បង្ហូរចុះមកដោយឥតព្រាងទុកទៅវិញ។

ក្នុងបន្ទប់ស្ងាត់ឈឹង! សំឡេងយោលនៃនាឡិកាធំរបស់ខ្ញុំ បានបន្លឺឡើងក្នុងអារម្មណ៍ដ៏សែនក្តុកក្តួល ខ្ញុំមិនដែលឮសំឡេងយោលរបស់នាឡិកាធំមួយនេះយ៉ាងនេះ នោះទេ ពីមុន។ បេះដូងរបស់ខ្ញុំលោតខុសចង្វាក់ ដុកដាក់ជាមួយនឹងសំឡេងយោលនៃប៉ោលនាឡិកានោះ។ ទឹកភ្នែកខ្ញុំម៉េចក៏ហូរចុះ។ ទឹកភ្នែកអើយ! អ្នកដឹងទេ! គ្មានបញ្ជារពីខ្ញុំ អ្នកមិនត្រូវហូរចុះនោះទេ អ្នកដឹងទេ? ខ្ញុំមិនដែលឲ្យទឹកភ្នែកមួយនេះ ស្រក់ចុះនោះទេ តាំងពីធំដឹងក្តីមក។ ហេតុអីក៏ពេលនេះ គេស្រក់ចុះមកដោយគ្មានអាសូរដល់ម្ចាស់នេត្ររបស់គេយ៉ាងនេះ? ឈប់យំទៅ ឈប់យំទៅ! T_T ខ្ញុំសួរអ្នកណាមានតែសួរខ្លួនឯង ចិត្តមួយតែងតែឧទានសួរមករហូតទៅវិញ... នារីនោះគេជានរណា ហ្ន៎?

យុទ្ធ! យុទ្ធមកវិញទេ? កំណាព្យយុទ្ធមិនមានសញ្ញាខណ្ឌបញ្ចប់ទេ។ អ៊ីចឹងយុទ្ធមកវិញហើយមែនទេ? មែនទេ? យុទ្ធមកវិញ ត្រូវទេ? .........T_T ហឺ......!

អត់ទេ... ហេតុអី ខ្ញុំត្រូវនឹកគេ? ខ្ញុំមិនដែលស្គាល់គេទេ។ ហេតុអីក៏ខ្ញុំនឹកគេ? ហេតុអី?

ខ្ញុំថែមសញ្ញាខណ្ឌឲ្យកំណាព្យយុទ្ធ។ ឆ្នាំនេះ ខ្ញុំមានអាយុ ៤០ឆ្នាំហើយ។ សម្រាប់ស្រ្តី ក្នុងវ័យនេះ គឺពិបាករកស្វាមី គូអនាគតហើយ។ ខ្ញុំបិទសៀវភៅទុក។ នេះជារឿង ដែលខ្ញុំធ្លាប់ជួបកាលពីខ្ញុំមានអាយុ២០ឆ្នាំជាង។ ខ្ញុំចាំថា បើតាមប៉ាខ្ញុំប្រាប់ យុទ្ធមានអាយុបងខ្ញុំដល់ទៅ៥ ឬ៦ឆ្នាំឯណោះ។ ខ្ញុំយកដៃជូតសំពត់ ហើយជូតភ្នែកដែលឪតដាម ទៅដោយទឹកភ្លៀងនៃដួងចិត្ត។

សំឡេងផ្គរលាន់បានបន្លឺឡើង ក្បែរបង្អួចនៃបន្ទប់ដាក់សៀវភៅរបស់ខ្ញុំ។ ទឹកភ្លៀងក៏ស្រក់ចុះមកស្រោចស្រប់ពេញទាំងធរណីដែលធ្លាប់តែក្តៅហែង។ សុបិននៃរដូវប្រាំង បានបញ្ចប់ទៅដោយ រីករាយ តែបង្កប់ទៅដោយ ភាពទុក្ខសោក។

អារម្មណ៍ទាំងឡាយក៏វិលត្រឡប់មករករឿងរ៉ាវក្នុងពេលបច្ចុប្បន្នកាលវិញ។ ខ្ញុំអង្គុយលើសាឡុងឈើក្នុងផ្ទះខ្ញុំ។ ខ្ញុំតែងក្រឡេកមើលពេលវេលាជានិច្ច។ រូបថតខ្ញុំ កាលពីក្មេងទាំងឡាយ ពេលនេះប្រែប្រួលអស់ហើយ គឺមិនដូចរូបខ្ញុំក្នុងពេលបច្ចុប្បន្ននេះសោះ។ ខ្ញុំចាស់ហើយ។

- លោកអ៊ុំៗ! មានគេផ្ញើអីជូនលោកអ៊ុំ!

ខ្ញុំភ្ញាក់ព្រឹតកាលបើបានឮសំឡេងក្អួយប្រុសរបស់ខ្ញុំ ទទឹកជោគ ហើយក្នុងដៃមានថង់មួយ ដែលដាក់ផ្កាឈូករ័ត្ន។ ខ្ញុំចាប់ថង់កាន់ ចំណែកក្អួយខ្ញុំក៏រត់ទៅលេងទៅភ្លៀងវិញ។ ខ្ញុំកាន់ផ្កាឈូករ័ត្នឡើង ពិនិត្យមើល។

ក្នុងឆ្នាំ២០១០ ស្រុកខ្មែរយើង មិនសូវនិយមប្រព័ន្ធអ៊ីនធឺណែតណាស់ណាអីទេ គឺគេនិយមមែល។ កាលណោះ ខ្ញុំចាំថា ខ្ញុំចេះលេងហ្វេសប៊ុគ តិចៗដែរហើយ។

មែនហើយ ចាប់តាំង ពីពេលដែលគេបានចាកចេញទៅទាំងស្ងៀមស្ងាត់ និងខ្ញុំបានអានទំហំចិត្តរបស់គេមក រាល់យប់ ខ្ញុំតែងសុបិនឃើញកុមារភាពដ៏សែនរីករាយរបស់ខ្ញុំពីមុននិងគេជានិច្ច។ តាមពិត គេជាសង្សារកុមារភាពរបស់ខ្ញុំ។ គេជាមនុស្សដំបូងដែលស្រឡាញ់ខ្ញុំ។ កាលណោះ គេជាបងជីដូនមួយសាច់ឆ្ងាយរបស់ខ្ញុំ។ គ្រប់ពេល គេតែងតែមកលេងផ្ទះខ្ញុំ។ ម៉ាក់ប៉ាគេ និងម៉ាក់ប៉ាខ្ញុំ ជិតស្និទ្ធិគ្នាណាស់។ ពួកគាត់រាប់អានគ្នាដូចបងប្អូនបង្កើតអ៊ីចឹង។ ខ្ញុំបាននឹកឃើញថា តាមពិត គេជាមនុស្សដំបូងហើយ ដែលធ្វើឲ្យខ្ញុំយំ ពេលដែលគេចេញទៅ។ មិនមែនជាសុបិនទេ តែជាកំណត់ហេតុដ៏វែងអន្លាយនៃជីវិតខ្ញុំ។ ខ្ញុំនិងគេបានបែកគ្នាតាំងពីអាយុ១០ឆ្នាំ។ កាលណោះ គេមានអាយុ១៥ឆ្នាំហើយ...

ប៉ុន្មានថ្ងៃក្រោយការចាកចេញរបស់គេ លោកប៉ា បានទូរស័ព្ទមកប្រាប់ខ្ញុំថា យុទ្ធបានជិះយន្តហោះផ្ទាល់ទៅ ប្រទេសកាណាដាវិញ តាមរយៈជើងយន្តហោះនៃខែត្រសៀមរាប។ សង្ឃឹមទាំងប៉ុន្មានបានរលាយអស់ ដូចពេលដែលយល់សប្តិហើយត្រូវគេដាស់អ៊ីចឹង។ ខ្ញុំកំពុងយល់សប្តិបើកភ្នែកហើយ។ ពីមនុស្សធ្លាប់នៅជាមួយគ្នា យើងក្លាយជាមនុស្សមិនស្គាល់គ្នា ហើយក៏ក្លាយជាមនុស្សរស់ដើម្បីបែកគ្នាទៅវិញ។

មិនដឹងជានិស្ស័យឬការរៀបចំទុកនៃព្រេងវាសនាទេ ល្ងាចឡើង ប៉ាបានមកភ្នំពេញ។ ពេលនោះគាត់ក៏យកអាសយដ្ឋានអ៊ីមែលមួយមកឲ្យខ្ញុំ អ៊ីមែលនោះគឺជារបស់សាយុទ្ធហើយ។ ខ្ញុំរីករាយណាស់។ តែខ្ញុំមិនបានទទួលពីប៉ាអីនោះទេ។ ប៉ាញ៉ាំកាហ្វេហើយ ហើយគាត់ដាក់អាសយដ្ឋាននោះលើតុ បន្ទាប់មក គាត់ក៏លាត្រឡប់ទៅវិញ។ ខ្ញុំយំក្នុងចិត្ត ពេលដែលខ្ញុំបានសារគេ។ ខ្ញុំបើកមើលយ៉ាងលឿន។ រួចហើយ បន់តែស្នេកនោះទេ ព្រោះស្នេកនេះ អ៊ីនធឺណែតក្បែរផ្ទះខ្ញុំ បើកដំណើរការវិញហើយ។

ព្រឹកឡើងបានចូលមកផ្លាស់វែន នៃប្រតិទិនរបស់ខ្ញុំ។ មេឃស្រទុំណាស់ ព្រឹកនេះ! ខ្ញុំតែងខ្លួនរួច។ ខ្ញុំក៏ទៅឆែកមែល នៅហាងអ៊ីនធឺណែត ដូចមុនចូលឆ្នាំ។ ខ្ញុំឃើញសារមួយបានលោតឡើង។ ខ្ញុំរីករាយណាស់ គិតថាប្រហែលនោះ ជាសាររបស់យុទ្ធហើយ តែបើកមើលទៅ គឺមិនមែននោះទេ។

វាជាសារបោកប្រាស់ថាឈ្នះរង្វាន់ទៅនៅអាមេរិក ប៉ុណ្ណោះ។ ខ្ញុំទាញកាបូបឡើង រួចបើកយកអាសយដ្ឋាន មែលរបស់យុទ្ធ ហើយព្យាយាមសាកល្បងសរសេរទៅគេមុនវិញម្តង។

ពេលកំពុងសរសេរ ស្រាប់តែសារមួយបានលោតចូលមក។ នោះជាសាររបស់យុទ្ធហើយ! ខ្ញុំទន្ទឹងយូរណាស់មកហើយ។ និយាយតាមត្រង់ចុះ លោកប៉ាមិនដឹងរឿងនេះនៅឡើយទេ។ ខ្ញុំតែងតែលាក់លោករហូត។ នេះជាសារទីមួយរបស់យុទ្ធ គូសង្សារវ័យក្មេងរបស់ខ្ញុំហើយ។ យុទ្ធបានប្រាប់ខ្ញុំថា គេនឹងវិលត្រឡប់ ក្នុងថ្ងៃណាមួយ នៅរដូវវស្សាខាងមុខ។ ផ្កាឈូករត្ន័ គឺជាតំណាងចិត្តស្មោះរបស់គេ។ គេថា សូមមេត្តាចាំគេវិលត្រឡប់វិញផង។

ពាក្យទាំងអស់ ខ្ញុំចាំទាំងអស់ គឺចាំគ្មានបាត់មួយពាក្យទេ។ ពិសេសជាងគេ គឺពាក្យថា «បងស្រឡាញ់អូន» នៅចុងក្រោយឃ្លានៃសារនោះ។ តាមពិត កំណត់ហេតុ ដែលគេភ្លេចនោះ គឺមិនមែនជារឿងចៃដន្យនោះទេ នេះជាការរៀបចំរបស់គេ។ «បងស្រឡាញ់អូន» នេះគឺជាពាក្យដែល មានពណ៌ស្រស់បំព្រងណាស់ក្នុងអារម្មណ៍របស់គូស្នេហ៍ ហើយពាក្យនេះហើយ គឺជាពាក្យដែល គេប្រើមុនគេបំផុតក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំមិនដឹងថាគេធ្លាប់ប្រើពាក្យនេះ ចំពោះនារីណាហើយនោះទេ តែគ្រាន់តែដឹងថាពាក្យមួយនេះ មានអត្ថន័យធំធេងសម្បើមណាស់ សម្រាប់ជីវិតនារីភេទដូចជាខ្ញុំ។ មួយជីវិតរបស់ខ្ញុំ ប្រហែលជាគ្មានអ្វីដែលធំធេងស្មើនឹងពាក្យដ៏ស្រស់ស្រទន់ និយាយចេញពីចិត្តមនុស្សដែលខ្លួនស្រឡាញ់ និងមនុស្សដែលស្រឡាញ់ខ្លួននោះទេ។ មេឃក៏ បង្អុលភ្លៀងមួយមេមក បញ្ជាក់ថារដូវវស្សាកំពុងតែឈានចូលមកហើយ...

មេឃរាំងភ្លៀងហើយ ហើយក៏រាំងពីអតីតកាលរបស់ខ្ញុំដែរ! ឥឡូវនេះ មេឃក៏បើកថ្ងៃ ក្នុងបច្ចុប្បន្នកាលរបស់មនុស្សម្តង។ ជាច្រើនវស្សាហើយ គេបានបាត់ដំណឹងសូន្យឈឹង។ ខ្ញុំដើរចេញទៅក្រៅឃើតៗ។ ខ្ញុំក្រឡេកឃើញខ្នងបុរសម្នាក់កំពុងជជែកជាមួយលោកប៉ាចំណាស់របស់ខ្ញុំ។

- គេចេញមកហើយ។ ប៉ាខ្ញុំមានប្រសាសន៍។

គេមានសម្បុលជ្រាវជ្រួញបន្តិច។ សក់របស់គេមានស្កូវតិចៗ។ បុរសម្នាក់នោះ កំពុងអង្គុយទល់មុខលោកប៉ា។ ពេលនេះ គេស្រាប់តែងាកមុខមករកខ្ញុំ។ គេងើបឡើង ហើយមើលមកមុខខ្ញុំ។ សំឡេងដ៏ផ្អែមពិរោះ តែធ្ងន់មានទឹកដមជាងមុន ក៏បានបន្លឺឡើងសារជាថ្មី ក្នុងត្រចៀករបស់ខ្ញុំ ដែលបានបាត់អស់ជាច្រើនឆ្នាំមកហើយ។

- នីដា!

ប្រហែលជាការរង់ចាំក្នុងសម័យទំនើបរបស់យុវវ័យសព្វថ្ងៃអស់តម្លៃហើយ បានជាពេលខ្លះ ខ្ញុំយល់ថា ខ្ញុំហាក់ដូចជាមនុស្សវិកលចរិតអ៊ីចឹង ពេលដែល នៅក្នុងកំណត់ហេតុរបស់ខ្ញុំ បានសរសេរពីការរង់ចាំរបស់ខ្ញុំចំពោះយុទ្ធ។ តែទោះជាយ៉ាងណាក៏ដោយ ក្តីស្រឡាញ់ដ៏ធំធេងមួយនេះ ជាក្តីស្រឡាញ់ដ៏អមតៈបំផុត នៃជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំនិងយុទ្ធ។ ស្នេហាមិនសំខាន់លើការរង់ចាំនោះទេ តែសំខាន់ទៅលើចិត្តនិងឆន្ទៈរបស់ដៃគូតែប៉ុណ្ណោះ។

ដៃរបស់យុទ្ធ បានគូស សញ្ញាត្រង់មួយ បន្ទាប់ពីសញ្ញាខណ្ឌ ដែលមានន័យថា ខណ្ឌបញ្ចប់ «៕» កំណត់ហេតុមួយ រឿងរ៉ាវពីររបស់យើងក៏បានកិបបញ្ចូលគ្នា។ ពួកយើងក៏នៅរួមរស់ជាមួយគ្នាអស់មួយជីវិត ប្រៀបបានជាមួយនឹង ផ្កាឈូករត្ន័ដែលរីកញញឹមមួយគូ។ ស្រស់ក៏ស្រស់ទាំងពីរ ស្រពោនក៏ស្រពោនទាំងពីរជារៀងរហូត៕